# ក្រុមពិគ្រោះយោបល់៖ ទិដ្ឋភាពរួមនៃការរីកចម្រើន

ក្រុមពិគ្រោះយោបល់ REDD+ (CG) ត្រូវបានស្នើឡើងនៅក្នុងផែនទីបង្ហាញផ្លូវដើម្បីត្រៀមលក្ខណៈសម្រាប់ REDD+ នៅកម្ពុជា (ដែលពីដំបូងបានលើកស្នើជា "ក្រុមផ្តល់យោបល់") ដែលជាស្ថាប័នមួយដែលអាចផ្តល់យោបល់ដល់ក្រុមការងារ REDD+ (TF) អំពីដំណើរការត្រៀមលក្ខណៈសម្រាប់REDD+និងផ្តល់ជាវេទិកាមួយ ដើម្បីធ្វើជាតំណាងឲ្យទស្សនៈរបស់ក្រុមអ្នកពាក់ព័ន្ធខុសៗគ្នា។ ក្រុមនេះត្រូវបានលើកស្នើបង្កើតឡើងក្នុងបំណងឲ្យទទួលខុសត្រូវផ្តល់ការទាក់ទងរវាងកម្មវិធី REDD+ នៅកម្ពុជា និងបណ្តាញដែលមានស្រាប់នៃក្រុមអ្នកពាក់ព័ន្ធនានា។

ក្រុម CG ត្រូវមានសមាជិក ១៨ រូប ដែលមានសមាជិក ២ រូបតំណាងឲ្យក្រុមអ្នកពាក់ព័ន្ធនីមួយៗ ក្នុងចំណោមក្រុមអ្នកពាក់ព័ន្ធចំនួន ៩។ ក្រុមទាំងនេះត្រូវបានលើកស្នើ នៅក្នុងផែនទីបង្ហាញផ្លូវ និងឯកសារកម្មវិធី UN-REDD និងផ្អែកលើការពិភាក្សាបន្ថែមជាមួយអ្នកពាក់ព័ន្ធនានា។ ក្រុមទាំង ៩ នេះគឺ៖

- គ្រឹះស្ថានសិក្សាស្រាវជ្រាវ
- អង្គការអន្តរជាតិ
- អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ
- អង្គការមិនមែនរដ្ឋាភិបាលជាតិ
- ពលរដ្ឋជាជនជាតិដើម
- អង្គការសង្គមស៊ីវិល
- វិស័យឯកជន
- ក្រុមសហគមន៍ព្រៃឈើ
- ក្រុមសហគមន៍តំបន់ការពារធម្មជាតិ
- ក្រុមសហគមន៍នេសាទ

ស្របគ្នាជាមួយគោលការណ៍ណែនាំអំពីការធ្វើឲ្យអ្នកពាក់ព័ន្ធចូលរួមនៅក្នុង UN-REDDផងដែរ អ្នកពាក់ព័ន្ធនានាមានភារៈទទួលខុសត្រូវជ្រើសរើសដោយខ្លួនឯងនូវតំណាងរបស់ពួកគេ។ នៅក្នុងករណីនៃក្រុមពលរដ្ឋជនជាតិដើម ដំណើរការជ្រើសរើសនេះត្រូវផ្អែកលើការប្រជុំបោះឆ្នោតនៅថ្នាក់ខេត្ត នៅក្នុងខេត្តចំនួន ១៥ ដែលមានជនជាតិដើមរស់នៅ។ វិធីបែបនេះត្រូវបានបង្កើតឡើងតាមរយៈការពិភាក្សាជាមួយតំណាងជនជាតិដើមភាគតិចនៅក្នុង និងនៅក្រោយមានការប្រជុំពិគ្រោះយោបល់អ្នកពាក់ព័ន្ធនៅក្នុងខែកញ្ញា ឆ្នាំ ២០១២។

ចំពោះក្រុមអ្នកពាក់ព័ន្ធផ្សេងទៀត ដើម្បីបញ្ចៀសការអះអាងថា រដ្ឋាភិបាលជាអ្នកមានឥទ្ធិពលមកលើដំណើរការនេះ "គណៈកម្មការសម្របសម្រួលស្ម័គ្រចិត្ត" (VFC) ត្រូវបានបង្កើតឡើង។ លិខិតអញ្ជើញមួយត្រូវបានផ្សព្វផ្សាយនៅខែធ្នូ ឆ្នាំ ២០១២ តាមរយៈសារព័ត៌មាន និងការផ្សព្វផ្សាយតាមប្រព័ន្ធអេឡិចត្រូនិក ការផ្សព្វផ្សាយតាមបណ្តាញ(អ៊ីម៉ែល) ដែលមានស្រាប់ និង តាមការនិយាយតគ្នាផ្ទាល់មាត់ ដែលស្នើដល់បុគ្គលនានាដែលមានចំណាប់អារម្មណ៍ ដាក់ជូនប្រវត្តិរូបរបស់ខ្លួន សារតាអំពីស្ថាប័ន និងការគាំទ្រក្នុងក្រុម នៅថ្ងៃទី ១០ ខែ មករា ឆ្នាំ២០១៣។

ចំនួនពាក្យសុំសរុបដែលទទួលបានគឺ ១៣ឈុត ដែលពាក្យសុំខ្លះ (ដែលភាគច្រើនបានពីនិស្សិត) ត្រូវបានចាត់ទុកថា មិនបំពេញតាមលក្ខណៈវិនិច្ឆ័យឡើយ។ កិច្ចប្រជុំមួយត្រូវបានរៀបចំឡើង ដើម្បីបង្កើតក្រុមនេះនៅខែ កុម្ភៈ ឆ្នាំ២០១៣ ដែលមានការសម្រេចថា សមាជិកស្ម័គ្រចិត្ត ១៩ រូប ដែលបានដាក់ពាក្យសំដែងចំណាប់អារម្មណ៍របស់ខ្លួន គួរតែបានទទួលការអញ្ជើញចូលរួមជាសមាជិក VFC ជាមួយមន្ត្រីទំនាក់ទំនងនៃ RTS ដែលមាននាទីជាលេខាធិការដ្ឋាន។ នៅពេលក្រោយមក ចំនួននេះត្រូវបានកាត់បន្ថយមកត្រឹម៩នាក់ ដោយសារសមាជិកស្ម័គ្រចិត្តមួយចំនួន បានបង្ហាញឲ្យឃើញថាមិនអាចផ្តោតពេលវេលាចាំបាច់របស់ខ្លួនដើម្បីរួមចំណែកនៅក្នុងការងាររបស់ VFCឡើយ។ អង្គការដូចខាងក្រោមនេះ មានតំណាងនៅក្នុង VFC៖

- លេខាធិការដ្ឋានក្រុមការងារ REDD+ (FiA)
- អង្គការផែក
- NTFP-EP
- វីនរ៉ក់អន្តរជាតិ
- USAID នៅកម្ពុជា
- Grandis Timer Limited (ក្រុមហ៊ុនស្ពាវព្រៃឈើពាណិជ្ជកម្ម)
- សមាគមយុវជនជាជនជាតិដើមកម្ពុជា (CIYA)
- ព្រះពុទ្ធសាសនាដើម្បីកម្ពុជា
- វេទិកាអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា

VFC បានជួបគ្នាចំនួន ១៣ លើក រវាងខែកុម្ភៈ និងចុងខែកក្កដា ដោយមានសមាជិកធ្វើជាប្រធានប្តូរវេននៅក្នុងការប្រជុំនីមួយៗ ដើម្បីសម្រេចអំពីទិដ្ឋភាពទាំងមូលនៃដំណើរការជ្រើសរើស CG ។ លទ្ធផលសំខាន់ៗនៃ VFC គឺ៖

- ការឯកភាពគ្នាលើលក្ខណៈវិនិច្ឆ័យដែលបេក្ខជនម្នាក់ៗត្រូវគោរពតាមក្នុងនាមជាសមាជិកនៃ CG ។ លក្ខណៈវិនិច្ឆ័យមានភាពខុសគ្នាទៅតាមក្រុមអ្នកពាក់ព័ន្ធនីមួយៗ។
- ការបង្កើតទម្រង់ប្លង់នៃដំណើរការជ្រើសរើស។ ដំណើរការនេះប្រហែលគ្នាសម្រាប់ក្រុមអ្នកពាក់ព័ន្ធទាំងអស់ លើកលែងតែសម្រាប់ជនជាតិដើមភាគតិច ដែលសម្រាប់ក្រុមនេះ មានការអនុវត្តដំណើរការបោះឆ្នោតនៅថ្នាក់ខេត្ត។
- ការឯកភាពគ្នាលើដំណើរការក្នុងការអញ្ជើញបេក្ខជននានាដាក់ជូនលិខិតសំដែងចំណាប់អារម្មណ៍។ ដំណើរការនេះរួមមានការផ្សព្វផ្សាយតាមវិធីចម្រុះ ដែលរួមទាំងតាមសារព័ត៌មាន និងតាមប្រព័ន្ធអេឡិចត្រូនិក និងតាមរយៈបណ្តាញ(អ៊ីម៉ែល) ដែលមានស្រាប់ និងការបង្ហោះនៅក្នុងវេបសាយ REDD+ នៅកម្ពុជាផងដែរ។
- ការពិនិត្យឯកសារពាក្យសុំ ដើម្បីធ្វើឲ្យប្រាកដថា បេក្ខជននានាឆ្លើយតបនឹងលក្ខណៈវិនិច្ឆ័យដែលបានកំណត់ និង បេក្ខជននានាត្រូវបានតែងតាំងនៅក្នុងក្រុមអ្នកពាក់ព័ន្ធនីមួយៗ។
- ទម្រង់ប្លង់ និងកាលកំណត់សម្រាប់សិក្ខាសាលាបោះឆ្នោតជ្រើសរើស CG (ដែលត្រូវធ្វើឡើងនៅថ្ងៃទី ៣០ ខែ សីហា ២០១៣)
- គំរូខុសៗគ្នាអំពីជម្រើសបោះឆ្នោត ដែលរួមទាំង ការបោះឆ្នោតដោយចំពោះនៅក្នុងសិក្ខាសាលា តាមប្រព័ន្ធអេឡិចត្រូនិក និងតាមប្រៃសណីយ៍ មុនពេលរៀបចំសិក្ខាសាលា។ ការបោះឆ្នោតតាមប្រៃសណីយ៍ មានបំណងឆ្លើយតបនឹងតម្រូវការរបស់ក្រុមគ្រប់គ្រងសហគមន៍ ដែលមានលទ្ធភាពក្នុងកម្រិតកំណត់ក្នុងការប្រើប្រាស់អ៊ិនធឺណិត ប៉ុន្តែមានតែបេក្ខជន ២ រូបប៉ុណ្ណោះសម្រាប់ក្រុមនីមួយៗ ដូចនេះការបោះឆ្នោតតាមប្រៃសណីយ៍មិនចាំបាច់ឡើយ
- ការកំណត់អត្តសញ្ញាណបញ្ជីឈ្មោះអ្នកបោះឆ្នោតសម្រាប់ក្រុមអ្នកពាក់ព័ន្ធនីមួយៗ
- រៀបចំសេចក្តីព្រាងគោលការណ៍ណែនាំប្រតិបត្តិសម្រាប់ CG (កំពុងអនុវត្ត)។

មានបេក្ខជនសរុបចំនួន ៣៣ នាក់ដែលបានដាក់ពាក្យចូលជាសមាជិក CG។ ៧ នាក់ក្នុងចំណោមបេក្ខជនទាំងនេះ (ភាគច្រើនជានិស្សិត) ត្រូវបានពិនិត្យអំពីកម្រិតឆ្លើយតបនឹងលក្ខណៈវិនិច្ឆ័យ ដោយសារតែបទពិសោធន៍មិនគ្រប់គ្រាន់។ ចំនួនបេក្ខជនសម្រាប់ក្រុមនីមួយៗគឺ៖

| ក្រុម | ចំនួន | យោបល់ |
|---|---|---|
| គ្រឹះស្ថានសិក្សាស្រាវជ្រាវ | ៣ | |
| អង្គការអន្តរជាតិ | ៤ | |
| ជាតិ | ៤ | |
| ក្រុមជនជាតិដើមភាគតិច * | ១៥ | ញែកដំណើរការកំណត់អត្តសញ្ញាណបេក្ខជនពីគ្នា |

| | | |
|---|---|---|
| អង្គការសង្គមស៊ីវិល | ៥ | |
| វិស័យឯកជន | ២ | ជ្រើសរើសតាមការទទះដៃអបអរសាទរ |
| សហគមន៍ព្រៃឈើ | ២ | ជ្រើសរើសតាមការទទះដៃអបអរសាទរ |
| សហគមន៍តំបន់ការពារធម្មជាតិ | ២ | ជ្រើសរើសតាមការទទះដៃអបអរសាទរ |
| សហគមន៍នេសាទ | ២ | ជ្រើសរើសតាមការទទះដៃអបអរសាទរ |

ដំណើរការបោះឆ្នោតតាមប្រព័ន្ធអេឡិចត្រូនិក បានធ្វើឡើងរវាងថ្ងៃទី ៩-២៣ ខែសីហា និងដើម្បីរក្សាភាពសម្ងាត់ និងឯករាជ្យភាពនៃសម្លេងឆ្នោត ដំណើរការនេះនឹងចាត់ចែងឡើងដោយបុគ្គលិកពីរូបមកពីក្រុម UN-REDD ថ្នាក់តំបន់។ សិក្ខាសាលាបោះឆ្នោត នៅថ្ងៃទី ៣០ ខែ សីហា នឹងធ្វើឡើង ដោយមានសិក្ខាសាលាផ្តល់ព័ត៌មានសម្រាប់បេក្ខជន CG ជាមុន។ អ្នកពាក់ព័ន្ធប្រមាណ ១២០នាក់ ដែលតំណាងឲ្យក្រុមអ្នកពាក់ព័ន្ធចំនួនទាំង ៩ នឹងបានអញ្ជើញឲ្យចូលរួមនៅក្នុងសិក្ខាសាលាបោះឆ្នោត។

បន្ទាប់ពីសិក្ខាសាលាបោះឆ្នោតនេះ CG នឹងបានទទួលការគាំទ្រដើម្បីចាប់ផ្តើមការងាររបស់ខ្លួនជាបន្ទាន់តាមតែអាចធ្វើបាន។ សកម្មភាពបង្កើនការយល់ដឹងនឹងត្រូវអនុវត្តសម្រាប់សមាជិក CG (និងសមាជិក TF) ដើម្បីធានាថា ពួកគេមានសមត្ថភាពក្នុងការផ្តល់យោបល់អំពីកិច្ចការដែលទាក់ទងនឹងការត្រៀមលក្ខណៈសម្រាប់ REDD+។

មានការរំពឹងថា CG នឹងប្រតិបត្តិការនៅក្រោមការចាត់ចែងដូចតទៅ៖

១. ក្រុមការងារ CG នឹងបោះឆ្នោតជ្រើសរើសប្រធានរបស់ខ្លួន ដោយមានប្រធានប្តូរវេន ក្នុងចំណោមក្រុមអ្នកពាក់ព័ន្ធទាំង ៩។ ប្រធាន RTS នឹងដើរតួជាលេខាធិការដ្ឋាន CG។
២. RTS នឹងរៀបចំរបៀបវារៈ និងការគាំទ្រដល់ការចងក្រងជាឯកសារ យ៉ាងហោចណាស់ម្តងក្នុងមួយខែ នៅមុនកិច្ចប្រជុំ TF នីមួយៗ និងចែករម្លែកឯកសារទាំងនេះជាមួយសមាជិកទាំងអស់នៃ CG។
៣. សមាជិក CG ត្រូវមានការទទួលខុសត្រូវផ្សព្វផ្សាយព័ត៌មានដល់ក្រុមអ្នកពាក់ព័ន្ធរបស់ខ្លួន និងស្នើសុំគំនិត និងយោបល់តប។
៤. CG នឹងជួបគ្នា ២ ថ្ងៃមុនការប្រជុំ TF ដើម្បីពិភាក្សាលើយោបល់តបដែលបានពីមណ្ឌល/ក្រុមអ្នកពាក់ព័ន្ធនីមួយៗ និងដើម្បីរៀបចំរបាយការណ៍បូកសរុបសម្រាប់ TF ។
៥. ប្រសិនបើមានការសម្រេចពី CG ប្រធាន ឬសមាជិកផ្សេងទៀតនៃ CG ត្រូវបង្ហាញជូនរបាយការណ៍ដល់ TF នៅក្នុងកិច្ចប្រជុំ TF។
៦. ការសម្រេចរបស់ TF នឹងត្រូវចែកផ្សាយទៅ CG ឲ្យបានឆាប់តាមតែអាចធ្វើបាន នៅក្រោយការប្រជុំនីមួយៗនៃ TF ហើយសមាជិក CG ត្រូវមានភារៈទទួលខុសត្រូវផ្សព្វផ្សាយព័ត៌មាននេះដល់មណ្ឌលរបស់ខ្លួន។
៧. RTS ក៏អាចស្នើសុំទៅ CG ដើម្បីផ្តល់យោបល់ ឬ គំនិតទៅក្នុងរបាយការណ៍ ឬ ឯកសារដទៃទៀត ដែលមិនមានបង្ហាញជូនដល់ TF។ CG នឹងធ្វើការសម្រេចថាតើ គំនិតនានា ត្រូវការឲ្យមានវិភាគទានពីមណ្ឌលដែលខ្លួកគេធ្វើជាតំណាងដែរឬទេ ដែលនៅក្នុងករណីនោះ គួរតែអនុវត្តដំណើរការប្រហែលគ្នានេះ សម្រាប់ឆ្លើយតបនឹងបញ្ហានានារបស់ TF ។

នៅក្នុងករណី<u>គ្រឹះស្ថានសិក្សាស្រាវជ្រាវ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាលជាតិ និងវិស័យឯកជន</u> មានការសន្មតថា មណ្ឌលដែលក្រុមអ្នកពាក់ព័ន្ធនានាធ្វើជាតំណាងមានលទ្ធភាពប្រើប្រាស់អ៊ីម៉ែល។ RTS នឹងរក្សាទុកបញ្ជីសមាជិកដែលមានសិទ្ធិបោះឆ្នោតនៃក្រុមទាំងនេះ និងចែកចាយបញ្ជីឈ្មោះដែលមានទៅឲ្យតំណាងនានានៃ CG នៅក្នុងក្រុមអ្នកពាក់ព័ន្ធទាំងនោះ ក្នុងបំណងចែកផ្សាយ និងស្នើសុំយោបល់តប។

នៅក្នុងករណី<u>អង្គការសង្គមស៊ីវិល</u> RTS ត្រូវធ្វើការប៉ាន់ប្រមាណអំពីលទ្ធភាពប្រើប្រាស់អ៊ីម៉ែល ហើយប្រសិនបើរកឃើញថាសមាជិកទាំងអស់ ឬសមាជិកភាគច្រើនមានលទ្ធភាពប្រើប្រាស់អ៊ីម៉ែល ដំណើរការដូចគ្នានេះនឹងត្រូវប្រើប្រាស់ ដូចជាមួយក្រុមអ្នកពាក់ព័ន្ធជាតំណាងទាំងបួនខាងលើផងដែរ និងជាការបំពេញបន្ថែម ប្រសិនបើចាំបាច់ត្រូវប្រើវិធីបោះឆ្នោតតាមប្រៃសណីយ៍។

នៅក្នុងករណីក្រុមជនជាតិដើមភាគតិច និង បណ្តាញគ្រប់គ្រងសហគមន៍ទាំងបី ការប្រើប្រាស់អ៊ីម៉ែល ពិតជាមិនគ្រប់គ្រាន់ឡើយ។ជាលទ្ធផល ដំណើរការសមស្របមួយ ដែលអាចអនុញ្ញាតឲ្យក្រុមនេះផ្សព្វផ្សាយព័ត៌មាន និងការស្នើសុំយោបល់តបត្រូវតែបានបង្កើតឡើង។

RTS ត្រូវផ្តល់ការគាំទ្រហិរញ្ញវត្ថុ ដល់អ្នកចូលរួម ដែលត្រូវធ្វើដំណើរពីមណ្ឌលរបស់ខ្លួន ដើម្បីចូលរួមការប្រជុំនានា។ ថ្លៃចំណាយសម្រាប់ការផ្សព្វផ្សាយព័ត៌មាន និងការទទួលបានយោបល់តប (ប្រសិនបើមាន) ត្រូវតែជាបន្ទុករបស់ RTS។

ត្រូវមានការផ្តល់មូលនិធិបន្ថែម សម្រាប់សកម្មភាពពិគ្រោះយោបល់ជាក់លាក់ និងការចូលរួម។